# របាំរាំវង់

ព្រះរាជាណាចក្រកម្ពុជា មានសិល្បៈវប្បធម៌សម្បូណ៌បែបបូរាណ និងអរូបិយរួមទាំងសិល្បៈទស្សនីយភាព មានតន្ត្រី ល្ខោន និងរបាំ ជាអាទិ៍របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ ដូចជារបាំបួងសួង អប្សរា និងទេពមនោរម្យ ដែលមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ។ របាំប្រពៃណី រស់នៅជាប់ជាមួយនឹងប្រជារាស្ត្រខ្មែរ ដូចជារបាំគោះត្រឡោក នេសាទ គ្រាប់ ច្រូតស្រូវ និងទន្សោង។ ឯរបាំប្រជាប្រិយ រួមមានរបាំរាំវង់ រាំក្បាច់ សារ៉ាវ៉ាន់ កន្ទ្រឹម តាលុង ឡាំលាវ ចូកកំពឹស ជាដើម។ល។ នៅទីនេះ ខ្ញុំសូមលើកយកតែរបាំរាំវង់មួយមកអធិប្បាយតែប៉ុណ្ណោះ។

គេរាំរបាំរាំវង់ ឬឡាំថូន (នាសម័យដើមនៅតាមទីជនបទ គឺរាំអាស្រ័យដោយស្គរថូន) ជារង្វង់មូលបញ្ច្រាសដំណើរនាឡិកា (Counter-clockwise) ដែលជាលក្ខណៈ និងកត្តាមួយឱ្យយើងហៅថា "រាំវង់"។ យើងរាំរបាំរាំវង់ជាគូៗ ស្រីមួយគូនឹងប្រុសមួយ ស្រីរាំពីមុខប្រុសរាំពីក្រោយ នៅជុំវិញតុផ្កាដែលគេរៀបចំដាក់នៅកណ្ដាលវេទិការាំជាស្នូល។ ចំពោះការរាំរាំវង់ គេមិនប្រកាន់ទីកន្លែង ឬពេលវេលាឡើយ គឺក្រោយពេលស្ទូងដក ច្រូតកាត់ បំពេញការហត្ថកម្ម ពេលជប់លៀង អាពាហ៍ពិពាហ៍ ឬបុណ្យនៅក្នុងគ្រួសារក៏គេអាចជួបជុំគ្នាសប្បាយរីករាយដោយមានការរៀបចំជាកម្មវិធីមានរបាំរាំវង់ផងដែរ។

ប្រជាជនខ្មែរ អ្នកនៅទីក្រុងក៏ដូចជាជនបទស្រែចម្ការ តំបន់ភ្នំ ឬខ្ពង់រាប តាមដងទន្លេ ឬឆ្នេរសមុទ្រ ជាអ្នកស្រឡាញ់សិល្បៈវប្បធម៌ និងចូលចិត្តសប្បាយរីករាយ ជាពិសេសនៅពេលច្រូតកាត់រួច ក្នុងពិធីបុណ្យទានប្រពៃណី និងសាសនាផ្សេងៗមានបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ បុណ្យផ្កា អុំទូកលយប្រទីបអកអំបុកសំពះព្រះខែជាដើម ដែលគេរមែងជួបជុំគ្នាលេងល្បែងប្រពៃណី និងរាំកម្សាន្តជាមួយនឹងរបាំរាំវង់និង របាំប្រជាប្រិយឯទៀត។ របាំរាំវង់ មានប្រជាប្រិយភាពណាស់ នៅក្នុងស្រទាប់ប្រជាជនខ្មែរ ពោលគឺខ្មែរគ្រប់គ្នាទាំងចាស់ ទាំងក្មេង ស្រី ប្រុស សុទ្ធតែចេះរាំរបាំរាំវង់ដែលមានភាពងាយស្រួលក្នុងការរៀនរាំ និងរាំ។

របាំរាំវង់ កំដរដោយវង់តន្ត្រីមួយវង់ ដែលមានទ្រ ស្គរដៃ និងអ្នកចម្រៀងដែលខ្មែរនៅតាម ជនបទ ហៅថា "ឡាំថូន"។ "ឡាំ" មានន័យថា "រាំ" និង "ថូន" គឺ "ស្គរ"។ ដូច្នេះ ឡាំ

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

ថូន មានន័យថា «រាំអាស្រ័យដោយស្គរថូន»។ នៅតាមទីក្រុង របាំរាំវង់ ត្រូវបានកំដរដោយវង់តន្ត្រី សម័យដែលមាន ហ្គីតារ អ៊ិក អាក់ត័រឌីអុង ក្រុមស្គរ និងអ្នកចម្រៀង។ វង់តន្ត្រីសម័យកំដររបាំរាំវង់ខ្នាតធំខ្លះ មានទាំងបញ្ចូលនូវឧបករណ៍គ្រឿងផ្លុំ និងខ្សែមួយចំនួនទៀតមានវីយ៉ូឡុង ខ្លុយដែក សាក់សូរ និងត្រុមប៉ែតផង។ ចម្រៀងរាំវង់ដែលមានប្រជាប្រិយភាពហើយខ្មែរសឹងតែគ្រប់គ្នាចេះ និងចងចាំនៅក្នុងខ្លួនមានដូចជាបទអាប៉ប់ពីយ៉ា (ហឹបពីយ៉ា (Happy Year)) ស្វាយចន្ទី រាំវង់អង្គរ អក្ខរា គន់មើលកផ្ការត្រូវខ្យល់ និងខ្យល់បក់រំភើយ ។ល។

យើងឃើញនៅកម្ពុជា ប្រជាជនខ្មែរមានរបាំរាំវង់នេះ ជាយូរយារណាស់មកហើយ។ របាំរាំវង់ក៏ជាទម្រង់របាំមួយដែលមាននៅជាប់ជិតស្និទ្ធជាទីបំផុតនឹងជនជាតិដើមភាគតិចមានគ្រឹង ទំពួន ព្រៅ កាចក់ ការ៉ែត ចារ៉ាយ ជាដើម ដែលគេច្រើនហៅថា "រាំវង់ភូមិថ្មី" ឬ "រាំវង់ស្រ៊ុកហាន់ទើម" ដោយសារតែគេរាំរបាំនេះនៅពេលបុណ្យទានប្រពៃណីនិងពិធីពាក់ព័ន្ធ នឹងជំនឿ ដូចជាពិធីលៀង អារក្ស ឡើងអ្នកតា កាប់ក្របី សែនព្រលឹង សែនស្រូវ និងជាពិសេសនៅពេលដែលគេផ្លាស់ប្តូរ ពីភូមិចាស់ទៅភូមិថ្មី បន្ទាប់ពីបានរស់នៅក្នុងភូមិចាស់ អស់រយៈពេលពីបីទៅប្រាំពីរឆ្នាំរួចហើយ ដើម្បីទៅរកដីថ្មីដែលមានជីរជាតិ ឬដោយសារគ្រោះ មហន្តរាយណាមួយ **មាន**ជំងឺឈឺស្កាត់ឬមរណភាពដែលមានដល់ប្រជាជននៅភូមិចាស់។ ជនជាតិភាគតិចខាងលើ ជួបជុំគ្នារាំលេងនៅលើទីលាននៃភូមិមូលរបស់គេ[1]។ ពេលខ្លះ យើងសង្កេតឃើញថា ជនជាតិដើមភាគតិច ក៏រាំលេងរបាំរាំវង់ភូមិថ្មីនេះនៅជុំវិញភ្នក់ភ្លើង នាពេលរាត្រីជាការកែកម្សាន្តដែរ។ ឯកសារខ្លះ បានអះអាងថា របាំរាំវង់មានការលូតលាស់បំផុតនៅក្នុងអំឡុងទសវត្សទី២០ ជាពិសេសចាប់ពីពេលចលនាតស៊ូតស្សូរៈ ដើម្បីទាមទារឯករាជ្យសេរីភាពពីអាណានិគមបារាំង[2]។

[1] ពេជ្រ ទុំក្រវិល ២០០៣: ទំព័រ៥៩

[2] ពេជ្រ ទុំក្រវិល ២០០១: ទំព័រ១៨៣

អត្ថបទដោយ៖ លោកបណ្ឌិត សំ សំអាង

## ឯកសារយោង

ចាប ពិន.

(១៩៦៤). *របាំប្រជាប្រិយខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ, ទុំក្រវិល.

(២០០០). *ស្បែកពណ៌និងស្បែកតូច*. ភ្នំពេញ: មូលនិធិតូយ៉ូតា។

ពេជ្រ ទុំក្រវិល.

(២០០១). *របាំខ្មែរ*. ភ្នំពេញ: មូលនិធិតូយ៉ូតា។

ពេជ្រ ទុំក្រវិល.

(២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

សំ សំអាង.

(២០០៣). *រាំវង់*. ភ្នំពេញ: សមាគមវប្បធម៌ខ្មែរ។

Catlin, Amy. (April 13-17, 1996). Doing the RoamVung and the Twist: The Cambodian Pop of Los Angeles, *The Los Angeles Weekly*.

Chen, Vivian, Jarrad, Magaly, and Sam, Chan Moly. (1993). Sharing Common Ground: Social Dancing in the U.S.A., *1993 Festival of American Folklife*. Washington, DC: Smithsonian Institution, pp. 63-68.

Sam, Sam-Ang and Campbell, Patricia. (1991*). Silent Temples, Songful Hearts: Traditional Music of Cambodia*. Danbury, CT: World Music Press.